**OMI0008**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## *សម្ភាសន៍ជាមួយ ទេព ប៉ូច អាយុ៦១ឆ្នាំ ភេទប្រុស*
## *មុខរបរៈក្រុមប្រឹក្សាឃុំ*
## *ភូមិស្វាយចេក ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ*
## *សម្ភាសន៍ដោយ ៈ ឡុង ដានី*
## *ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០០៨*

***កាសែ្សតទី១ខាងអេ***

*ដានីៈ* *ខ្ញុំប្រាប់អ៊ីមួយសារទៀតថាពួកខ្ញុំហ្នឹងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងមានតួនាទីប្រមែប្រមូលឯកសារក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ហើយការប្រមែប្រមូលនិងយើងមានការអនុញ្ញាតិពីរដ្ឋាភិបាលដែលឲ្យយើងធ្វើកិច្ចការទាំងអស់ហ្នឹង ។*

*ប៉ូចៈ* *បាទ ។*

*ដានីៈ* *ហើយការចងក្រងទាំងអស់និងទុកជាឯកសារប្រវត្តិសាស្រ្ត ទុកឲ្យក្មេងៗជំនាន់ក្រោយធ្វើការស្រាវជ្រាវដែលគេចង់ស្រាវជ្រាវពីរបប៧៥ដល់៧៩ហ្នឹងគេអាចទៅអានកន្លែងនិងបាន ហើយខ្ញុំមកជួបអ៊ីនេះគឺចង់ដឹងរឿងរ៉ាវផ្ទាល់ខ្លួនអ៊ីខ្លះៗនៅក្នុងសម័យបីឆ្នាំហ្នឹងប្តូក៏ក្រោយបីឆ្នាំមកសួរពីកន្លែងតស៊ូអីយ៉ាងម៉េចៗអ៊ី ។*

*ប៉ូចៈ* *បាទ ។*

*ដានីៈ* *ជាពិសេសទៀតខ្ញុំចង់ដឹងពីទំនាក់ទំនងល្អ រវាងអ៊ីជាមួយប្រជាជនដែលមិនមែនជាអ្នកមូលដ្ឋាននៅថ្មីហ្នឹង អ៊ីធ្លាប់មានទំនាក់ទំនងអីខ្លះ ធ្លាប់បានជួយអីខ្លះដល់ពួកគាត់ណាស់ ។*

*ប៉ូចៈ* *បាទ ។*

*ដានីៈ* *បើសិនជាអ៊ីមានអអាចជួយជំរាបប្រាប់ខាងខ្ញុំផង ។*

*ប៉ូចៈ* *បាទ ។*

*ដានីៈ* *ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ី អ៊ីឈ្មោះអីដែរ?*

*ប៉ូចៈ* *ខ្ញុំឈ្មោះទេព ប៉ូច ។*

*ដានីៈ* *អ៊ីអាយុប៉ុន្មានហើយសព្វថ្ងៃ?*

*ប៉ូចៈ* *ខ្ញុំកើតឆ្នាំ១៩៤៧ ស្មើនិង៦០ប៉ុន្មានហើយ ។*

*ដានីៈ* *៦១?*

ប៉ូចៈ ខ្ទង់ប៉ុណ្ណឹងហើយ ។

ដានីៈ គ្រួសារអ៊ឹឈ្មោះអីដែរ?

ប៉ូចៈ គ្រួសារខ្ញុំបីហើយ នៅសព្វថ្ងៃនេះទី៣ ។

ដានីៈ បាទ!ឈ្មោះអីទៅ?

ប៉ូចៈ ឈ្មោះហោម សាន ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

ប៉ូចៈ គាត់អាយុខ្ទង់៤២ឬ៤៣ ។

ដានីៈ អ៊ឹមានកូនចៅប៉ុនាននាក់ដែរ?

ប៉ូចៈ កូនចៅខ្ញុំមាន៨នាក់ គ្រួសារខ្ញុំកូនប្តីមុននោះមួយតែខ្ញុំជាមួយគ្រួសារសព្វថ្ងៃនេះមានកូនបីនាក់ ។

ដានីៈ បាទ!ជាជំទប់ទី?

ប៉ូចៈ ខ្ញុំជាសមាជិកក្រុមប្រឹក្សាឃុំ ។

ដានីៈ សព្វថ្ងៃអ៊ឹរស់នៅភូមិឃុំស្រុកអីដែរ?

ប៉ូចៈ សព្វថ្ងៃខ្ញុំរស់នៅភូមិស្វាយចេក ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ដានៈ ឪពុកម្តាយអ៊ឹឈ្មោះអីដែរ?

ប៉ូចៈ ឪពុកឈ្មោះប៉ោម ម្តាយឈ្មោះយ៉ែម ។

ដានីៈ ចឹងសព្វថ្ងៃគាត់ទាំងពីរ?

ប៉ូចៈ គាត់ស្លាប់អស់ហើយ ។

ដានីៈ គាត់នៅណាដែរ?

ប៉ូចៈ គាត់នៅខេត្តកំពង់ស្ពឺ ។

ដានីៈ ចឹងស្រុកកំណើតរបស់អ៊ឹនៅកំពង់ស្ពឺ?

ប៉ូចៈ បាទ ។

ដានីៈ នៅភូមិអីគេ?

ប៉ូចៈ នៅភូមិតាំងរលាំង ។

ដានីៈ ឃុំអី?

ប៉ូចៈ ឃុំវាលពង់ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

ដានីៈ ចឹងអ៊ឹមានបងប្អូនប៉ុន្មាននាក់ដែរ?

ប៉ូចៈ មានបងប្អូនបួននាក់ ។

ដានីៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ប៉ូចៈ ស្រី១ ប្រុស៣ ។

ដានីៈ អ៊ីកូនទីប៉ុន្មាន?

ប៉ូចៈ ខ្ញុំកូនទី៣ ។

ដានីៈ ចឹងអ៊ីជួយរៀបរាប់រឿងរ៉ាវរបស់អ៊ីតាំងពីតូចរហូតមកឆ្លងកាត់នៅសម័យប៉ីឆ្នាំ ក្រោយសម័យប៉ីឆ្នាំមកបានធ្វើនៅកន្លែងណាខ្លះ?

ប៉ូចៈ បាទ ។

ដានីៈ ជួយរៀបរាប់ជាសង្ខេប?

ប៉ូចៈ តាំងពីតូចមកខ្ញុំរស់នៅក្នុងបន្ទុកឪពុកម្ដាយ ។

ដានីៈ បាទ ។

ប៉ូចៈ ក្រោយមកខ្ញុំពេញវ័យទៅខ្ញុំទៅនៅវត្តបានបួសរៀនបានពីរវស្សា ។

ដានីៈ បានបួសពីរវស្សានៅវត្តណា?

ប៉ូចៈ បួសនៅវត្តតាំងខ្មៅ ។

ដានីៈ ហើយយ៉ាងម៉េចទៀត?

ប៉ូចៈ ក្រោយមកទៀតខ្ញុំសឹកមកឪពុកម្ដាយខ្ញុំរៀបចំគ្រួសារឲ្យ ហើយក្រោយមកស្លាប់ប្រពន្ធមួយទៅហើយខ្ញុំក៏បានឮការអំពាវនាវរបស់សម្ដេចថាឲ្យចូលព្រៃម៉ាគីទៅ ។

ដានីៈ បាទ ។

ប៉ូចៈ ហើយចេះតែឃើញគេឃើញឯងចឹងទៅចេះតែដោយរោយតាមគេរហូតចឹងមក ។

ដានីៈ បាទ ។

ប៉ូចៈ ចឹង ។

ដានីៈ កាលអ៊ីបួសនៅឆ្នាំណាដែរ?

ប៉ូចៈ កាលហ្នឹងមិនដឹងជាឆ្នាំ១៩៦០ប៉ុន្មានទេភ្លេចហើយប្រហែលជា៦៤-៦៥អីហ្នឹង ។

ដានីៈ ចឹងអ៊ីរៀបការនៅឆ្នាំណា?

ប៉ូចៈ រៀបការឆ្នាំ១៩៦៨ ។

ដានីៈ អ៊ីការបានប៉ុន្មានឆ្នាំបានប្រពន្ធអ៊ីគាត់ស្លាប់?

ប៉ូចៈ ការបានបួនឆ្នាំ ។

ដានីៈ គាត់ស្លាប់ដោយសារមូលហេតុអី?

ប៉ូចៈ គាត់ស្លាប់ដោយសារជំងឺអាសន្នរោគ ។

ដានីៈ ចឹងការមានកូនចៅដែរ?

ប៉ូចៈ កូនមានកូនបានបួនខែពេលម៉ែស្លាប់បានបួនខែទៅកូននោះក៏ស្លាប់ទៅដែរ ។

ដានី៖ មានកូនតែមួយនិងទេ?

ប៉ូចៈ បាទ ។

ដានី៖ ប្រពន្ធឈ្មោះអី?

ប៉ូចៈ ប្រពន្ធស្លាប់ទៅហ្នឹងឈ្មោះសែម ។

ដានី៖ ចឹងអំពូប្រកាសរបស់សម្តេចព្រះនរោត្តម សីហនុនៅឆ្នាំណា?

ប៉ូចៈ ឆ្នាំ១៩៧០ ។

ដានី៖ ៧០ប៉ុន្មាន?

ប៉ូចៈ ឆ្នាំ៧០-៧១អីហ្នឹង ។

ដានី៖ ចឹងពេលដែលអំពូការឃោសនារបស់សម្តេចព្រះនរោត្តមសីហនុចឹងទៅអ៊ំយ៉ាងម៉េច?

ប៉ូចៈ ឃើញគេបបួលគ្នាចូលព្រៃម៉ាគីឃើញគេទៅ ក៏ទៅតាមគេតាមឯងចឹងទៅ ។

ដានី៖ ចូលទៅខាងណាព្រៃម៉ាគីហ្នឹង?

ប៉ូចៈ កាលនោះគេហៅអីទេ គេហៅរណៈសិរ្សរួបរមជាតិកាលជំនាន់នោះ ។

ដានី៖ ចឹងយ៉ាងម៉េចទៀតទៅ?

ប៉ូចៈ កាលហ្នឹងតស៊ូទៅក៏បានទៅរស់នៅជាមួយគេតាំងពី៧១-៧២ចឹងមកណាស់ ។

ដានី៖ បាទ ។

ប៉ូចៈ ហើយរហូតមកបន្តបន្ទាប់មកខ្លួនខ្ញុំហ្នឹងក៏បានរួមតស៊ូជាមួយគេហៅថាអន្តភាពឃុំ ហើយពីហ្នឹងមកក៏បានទទួលខុសត្រូវក្នុងមូលដ្ឋានឃុំបានមួយរយៈមកឆ្នាំ១៩៧៣-៧៤ចឹងមកខ្ញុំទៅនៅខាងត្បូងផ្លូវលេខ៤ ។

ដានី៖ នៅហ្នឹងធ្វើអីទៅ?

ប៉ូចៈ នៅហ្នឹងទទួលខុសត្រូវប្រជាជនខាងអប់រំប្រជាជន បានរហូតដល់ឆ្នាំ១៩៧៥ចឹងទៅ ។

ដានី៖ ចឹងទទួលអប់រំប្រជាជនមួយឃុំ?

ប៉ូចៈ បាទ ។

ដានី៖ កាលហ្នឹងនៅឃុំអីគេកាលហ្នឹង?

ប៉ូចៈ ឃុំកាលហ្នឹងឃុំកន្ទុក ។

ដានី៖ ស្រុកអីគេ?

ប៉ូចៈ ស្រុកកាលហ្នឹងដូចជាស្រុកកណ្តាលស្ទឹងឬក៏ស្រុកដង្កោលទេភ្លេចហើយ ។

ដានី៖ ចឹងកាលអ៊ំតស៊ូនៅព្រៃកាលឆ្នាំ៧១-៧២-៧៣ហ្នឹងអ៊ំតស៊ូនៅអន្តភាពឃុំណា?

ប៉ូចៈ អន្តភាពឃុំមិញហ្នឹងប្រាប់ហ្នឹង ឃុំកន្ទុក ស្រុកកណ្តាលស្ទឹង ។

ដានី៖ អ៊ំទទួលខុសត្រូវប្រជាជនឃុំហ្នឹង?

ប៉ូចៈ បាទ! កាលទទួលហ្នឹងមិនបានប្រជាជនមកច្រើនទេ គឺយើងនៅក្រោលណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ នៅខាងក្រៅមិនមែននៅខាងក្នុងទេ ។

ដានីៈ បាទ ។

ប៉ូចៈ តែជួបមួយជួបពីរចឹងទៅ នៅហូរហែរចឹងទៅណាស់ ហើយដល់ក្រោយមកប្រជាជនចេះតែចេញពីភ្នំពេញហ្នឹងមកខ្ញុំចេះតែអប់រំទទួលខុសត្រូវនៅខាងក្រោយ ដែលមានកន្លែងមួយកន្លែងចឹងទៅណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ មានមូលដ្ឋានសម្រាប់អប់រំហើយដោះស្រាយស្បៀងសម្រាប់ប្រជាជនចឹងទៅណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ ដល់ពេលប្រជាជនខ្វះបាយខ្វះទឹកអីហូបចឹងទៅ ខ្ញុំបាទហ្នឹងខាងស្រុកត្រូវជ្រើសរើសឲ្យទៅទាក់ទងទៅខាងទន្លេចឹងមកឲ្យទៅរកពោតរកអង្ករយកមកផ្តល់ឲ្យប្រជាជននៅហ្នឹង ។

ដានីៈ នៅឆ្នាំណា?

ប៉ូចៈ នៅឆ្នាំ១៩៧៤ ។

ដានីៈ បាទ ។

ប៉ូចៈ ហើយពីហ្នឹងមកចេះតែនាំប្រជាជនធ្វើស្រែធ្វើចំការ ដើម្បីផ្គត់ផ្គង់គាត់ចឹងទៅបានដល់ឆ្នាំ៧៥ ទៅចប់សង្គ្រាមទៅក៏ប្រជាជនរៀបដាក់តាមកន្លែងភូមិឃុំរបស់គាត់វិញទៅ ។

ដានីៈ បាទ ។

ប៉ូចៈ ហ្នឹងចឹងនិយាយពីសាច់រឿងផ្ទាល់ខ្លួនរបស់ខ្ញុំកន្លងមកគឺប៉ុណ្ណឹង ។

ដានីៈ ចុះដល់ឆ្នាំ៧៥?

ប៉ូចៈ ដល់រំដោះឆ្នាំ៧៥ ហើយនិងគឺខ្ញុំខាងខេត្តខាងតំបន់ហ្នឹង ចាត់តាំងឲ្យខ្ញុំទទួលខុសត្រូវប្រជាជនជាសមាជិកនៅក្នុងស្រុកស្អាង បានរយៈពេលមួយឆ្នាំបានជាអនុប្រធានស្រុកធ្វើការងារនៅស្រុកស្អាងហ្នឹងបានមួយឆ្នាំដែរ ឆ្នាំ៧៦នៅស្រុកស្អាងដល់ខែ៧ខាងខេត្តខាងភូមិភាគអីបានចាត់តាំងឲ្យខ្ញុំមកភូមិភាគកណ្តាល ។

ដានីៈ មកធ្វើអីទៅភូមិភាគកណ្តាលហ្នឹង?

ប៉ូចៈ មកហ្នឹងមកធ្វើស្រុកទទួលខុសត្រូវក្នុងស្រុកហ្នឹងដែរ ។

ដានីៈ មកស្រុកអីដែលភូមិភាគកណ្តាល?

ប៉ូចៈ ខ្ញុំមកនៅស្រុកតាំងគោក ។

ដានីៈ មកធ្វើជាប្រធានស្រុកតាំងគោកហ្នឹង?

ប៉ូចៈ បាទ!មកហ្នឹងជាប្រធានហ្នឹងខ្ញុំជាអ្នកថ្មីហើយខ្ញុំជាអ្នកទៅពីឆ្ងាយ ហើយការងារទាំងអស់គឺនៅលើអនុលេខាហើយនិងសមាជិក ដែលគាត់ស្គាល់ទីនោះកន្លែងនោះខ្ញុំនិងគ្រាន់តែក្នុងនាមជាប្រធាន ។

ដានីៈ បាទ ។

ប៉ូចៈ ធ្វើការងារហ្នឹងបានមួយរយៈបានប្រហែលជា៧ទៅ៨ខែ ដឹកនាំប្រជាជនធ្វើស្រែធ្វើស្រូវអីទៅ ។

ដានីៈ បាទ ។

ប៉ូចៈ កាលហ្នឹងបានដោះស្រាយស្បៀងបានស្រូវរាប់សែនថាំងទៅណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ ដ្កត់ដ្កង់នៅកន្លែងហ្នឹងបានប្រហែលជា៧ខែ ។

ដានីៈ ឆ្នាំណាហ្នឹង?

ប៉ូចៈ ដូចជាភ្លេចហើយក្នុយខ្ញុំធ្វើស្រែហើយហ្នឹង ច្រូតហើយហ្នឹងដល់ខែប៉ុន្មានទេខ្ញុំនៅបាន៧ខែចឹងទៅនៅស្រុកនោះបាន៧ខែទៀត ។

ដានីៈ អ៊ីផ្លាស់ចេញពីតាំងគោកហ្នឹងប្រហែលជាខែប្រាំងខែវស្សា?

ប៉ូចៈ ខ្ញុំមកដល់ច្រូតហើយរៀបធ្វើស្រែប្រាំង ខ្ញុំមកធ្វើស្រែប្រាំង មកធ្វើស្រែប្រាំងបានបីបួនខែគ្រាន់ស្ទូងហើយមិនបានហ្នឹង ។

ដានីៈ ស្ទូងស្រូវវស្សា?

ប៉ូចៈ បាទ! ស្ទូងស្រូវប្រាំងដល់ពេលឆ្នាំហ្នឹងទឹកលិចស្រូវអស់ ។

ដានីៈ បាទ ។

ប៉ូចៈ លិចស្រូវអស់ទៅក៏រៀបចំធ្វើស្រូវប្រាំងហ្នឹងទៅមិនទាន់បានផងក៏ដល់ឆ្នាំ១៩៧៩ខែ១២ក៏កើតព្រឹត្តិការណ៍ហ្នឹងឡើង ។

ដានីៈ បាទ!ចឹងអ៊ីមកនៅតាំងគោកហ្នឹងបាន៧ខែអ៊ីទៅណាទៀត?

ប៉ូចៈ ផ្លាស់មកស្រុកបារាយណ៍វិញ ។

ដានីៈ ហ្នឹងនៅក្នុងតំបន់តែមួយឬតំបន់ផ្សេងគ្នា?

ប៉ូចៈ តំបន់តែមួយទេ ។

ដានីៈ តំបន់ប៉ុន្មាននៅហ្នឹង?

ប៉ូចៈ កាលនោះគេហៅតំបន់៤២ ។

ដានីៈ កាន់នៅស្រុកបារាយណ៍បានរយៈពេលប៉ុន្មាន?

ប៉ូចៈ ដូចជាមិនបានមួយឆ្នាំផងទេ ខ្ញុំមិនបានចាំខែដែលណាក្នុយ ។

ដានី: បាទ!ចឹងមកទទួលស្រុកបារាយណ៍ហ្នឹងរហូតដល់កើតព្រឹត្តិការណ៍?

ប៉ូចៈ បាទ!ដល់កើតព្រឹត្តិការណ៍៧៩ហ្នឹង ។

ដានី: ចឹងខ្ញុំចង់ជំរាបសួរលោកអ៊ំបន្តិចថាតាំងពីអ៊ំបានធ្វើជាអនុលេខាស្រុកស្អាង មកលេខាតាំងគោគនិងមកស្រុកបារាយណ៍ហ្នឹងអ៊ំមានធ្លាប់រាប់អាននិងមានទំនាក់ទំនងល្អជាមួយប្រជាជនដែលជាប្រជាជនថ្មីឬជាប្រជាជនដែលមិនមែនជាអ្នកមូលដ្ឋានណាស់អ៊ំមានធ្លាប់មានទំនាក់ទំនងល្អអីដែលឬអត់?

ប៉ូចៈ រឿងខ្ញុំមួយមិនមែនចេះតែលើកហើយក៏មិនមែនចេះតែនិយាយទេ ការពិតចំពោះផ្ទាល់ខ្លួនខ្ញុំ ខ្ញុំបានរៀនពីជីវធម៌រស់នៅក្នុងសង្គមហើយក៏បានរៀនសូត្រខាងព្រះពុទ្ធសាសនាខាងផ្លូវធម៌អារ ។

ដានី: បាទ ។

ប៉ូចៈ សូម្បីតែឪពុកម្តាយខ្ញុំគាត់ជាអ្នកស្មោទានសិលបន្តបន្ទាប់មករហូត ហើយខ្ញុំនិងក៏មិនមែនជាមនុស្សឆេវឆាវហើយក៏មិនមែនជាមនុស្សដែលគ្មានដឹងខុសដឹងត្រូវអ៊ីដែលខុសអ៊ីដែលត្រូវអ៊ីដែលល្អអ៊ីដែលមិនល្អនោះ ខ្ញុំក៏បានពិចារណាចំពោះខ្លួនខ្ញុំច្រើនដែលមិនថាប្រជាជនចាស់មិនថាប្រជាជនថ្មីទេ ខ្ញុំមិនមែនចេះតែនិយាយទេក្មួយដឹងស្រាប់ហើយ ។

ដានី: បាទ ។

ប៉ូចៈ បើយើងនិយាយអីមិនបានគិតបើយើងធ្វើអីដោយមិនមានការពិចារណាទេ យើងរងចាំតែថ្ងៃស្លាប់ទេបាទ ។

ដានី: បាទ ។

ប៉ូចៈ ខ្ញុំគាប់ជួនពេលដែលគេជ្រើសរើសសមាភាព១៧មេសាឬក៏គេជ្រើសរើសទាហានជំនាន់នោះគេហៅថាជ្រើសរើសអ្នកសមាភាពណាស់ ។

ដានី: បាទ ។

ប៉ូចៈ ខ្ញុំនិយាយចំពោះមុខក្មួយផាល់ គឺខ្ញុំមិនដែលទៅរាយការណ៍ឬទៅចុចឈ្មោះថាអ្នកនេះធ្វើនេះ អ្នកនោះធ្វើនោះចំហរខ្ញុំ ខ្ញុំប្រកាន់ចឹងព្រោះក្មួយយល់ស្រាប់ហើយខ្ញុំទៅពីចម្ងាយ ។

ដានី: បាទ ។

ប៉ូចៈ ខ្ញុំមិនដឹងពីប្រវត្តិរបស់ប្រជាពលរដ្ឋឬជាបងប្អូនដែលអីៗនៅក្នុងស្រុកនៅក្នុងភូមិ ខ្ញុំប្រាប់អនុលេខានិងសមជិកទាំងអស់ខ្ញុំថាខាងលើគេឲ្យតាមដានតែមនុស្សណាដែលមានសកម្មភាពប្រឆាំងបក្សគេជំនាន់នោះណាស់ ។

ដានី: បាទ ។

ប៉ូចៈ យើងមិនមែនតែឃើញគេខុសអីហើយចេះតែចាប់ផ្ទាក់គឺអត់ទេ ថ្ងៃមួយឈ្លបសហករណ៍នៅឃុំគ្រើល ។

ដានីៈ ឃុំអីគេ?

ប៉ូចៈ ឃុំគ្រើលនៅតាំងគោគ ប្រជាជនយុវជនយុវនារីដែលគ្នាឃ្លានបាយណាស់ គ្នាអត់ហូបណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ គ្នាទៅដាំបាយដល់ទៅដាំបាយទៅកាប់មាន់ស្ងោ ដល់គ្នាដាំឆ្អិនស្ងោមាន់ឆ្អិនក៏ទៅចាប់គ្នាមកចាប់គ្នាមកក៏យកមាន់ស្ងោនិងបាយនិងទៅហូបអស់ ។

ដានីៈ បាទ ។

ប៉ូចៈ បានវាមករាយការណ៍ឲ្យខ្ញុំ ខ្ញុំថាយើងធ្វើហ្នឹងវាមិនត្រូវទេយើងអត់ហូបយើងឃ្លានយ៉ាងម៉េច ចុះឯងចំពោះរូបគេ គ្នាក្មេងៗកំពង់ពេញវ័យគ្នាពេញហូបចុកគ្នាឃ្លានយ៉ាងម៉េច បើយើងទៅយកពីគេហើយគំរៀមគំហែងគេហើយយកកំហុសដាក់ទៅលើគេ តើវាត្រឹមត្រូវទេ ។

ដានីៈ បាទ ។

ប៉ូចៈ ដល់ចឹងហៅមកហៅទាំងប្រធានសហករណ៍ហៅទាំងប្រធានឈ្លបថាយើងធ្វើចឹងវាមិនត្រឹមត្រូវទេ ខ្ញុំថាអត់មានត្រូវការធ្វើចឹងទេ ដល់ចឹងទៅអ្នកនោះឯងគឺភ័យខ្លួនអាហ្នឹងមួយ តែមួយទៀតខ្ញុំមកនៅស្រុកបារាយណ៍ពេលប្រជាជនគាត់មានធុរៈ សាច់ញាតិគាត់ស្លាប់នៅក្នុងផ្ទះ ។

ដានីៈ បាទ ។

ប៉ូចៈ ស្លាប់នៅក្នុងផ្ទះប្រហែលជាគ្នាប្អូនដប់នាក់ គាត់កំពង់តែធ្វើបុណ្យបាំងស្កូលសូត្រធម៌ដុតធូបណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ ពេលហ្នឹងខ្ញុំជិះម៉ូតូទៅដល់គាត់ភ័យញ័រ ដល់គាត់ញ័រចឹងទៅខ្ញុំក៏ឈប់ម៉ូតូហើយហៅគាត់មកជួប ខ្ញុំថាអឹងឯងទាំងអស់គ្នាធ្វើបុណ្យធ្វើចុះ តែសម័យនេះអឹងឯងត្រូវដឹងហើយតែធំក្លិនភ្លើងធូបហើយនិងគេពុនរាប់ហើយយើង ខ្ញុំថាចឹង ។

ដានីៈ បាទ ។

ប៉ូចៈ ខ្ញុំក៏ថាឥឡូវយើងធ្វើអីធ្វើឲ្យលឿន បិទទ្វារធ្វើបើធ្វើហើយយកទៅកប់ទៅយកទៅទុកយកទៅដាក់ទៅ ។

ដានីៈ បាទ ។

ប៉ូចៈ		គាត់ក៏នៅធ្វើទៅខ្ញុំក៏ចុះទៅស្រែទៅ ។

ដានីៈ		ប្រជាជននៅណា?

ប៉ូចៈ		ប្រជាជននៅបារាណ៍ ។

ដានីៈ		ប្រជាជនថ្មីឬជាប្រជាជនមូលដ្ឋាន?

ប៉ូចៈ		ប្រជាជនមូលដ្ឋាននៅហ្នឹងហើយ ។

ដានីៈ		ភូមិហ្នឹងគេហៅភូមិអីអឹមានចាំទេ?

ប៉ូចៈ		ភូមិត្រង់ហ្នឹងគេហៅភូមិអូស្តីយ៉ាងម៉េចទេ ភ្លេចហើយត្រង់ហ្នឹងនៅជិតផ្សារពីដើមហ្នឹងណាស់ ។

ដានីៈ		បាទ ។

ប៉ូចៈ		នៅជាប់ផ្លូវជាតិហ្នឹង ខ្ញុំឲ្យធ្វើទៅសូម្បីហូបបាយលួចអង្ករព្រៃអីខ្ញុំមិនឲ្យនិយាយទេ ។

ដានីៈ		បាទ ។

ប៉ូចៈ		អាហ្នឹងមួយដែលកាលខ្ញុំបានជួយហើយក្រៅពីហ្នឹងគាត់ហូបទឹកត្នោតដូចង់អី គាត់បំពៅមួយបំពង់ពីរបំពង់ចឹងទៅ ខ្ញុំថាធ្វើម៉េចកុំឲ្យធំក្លិនដល់គេហូបៗចុះសម្រាប់កែរោគរបស់យើង ។

ដានីៈ		បាទ ។

ប៉ូចៈ		បើគេសួរយើងអាចមានពាក្យដោះស្រាយជាមួយគេដែរ ព្រោះរឿងសុខភាព ។

ដានីៈ		បាទ! ដោយសារអឹជាគណៈស្រុកចឹងហើយ តើអឹខ្លាចពីណាជីងពីណាទាន់ទៀត?

ប៉ូចៈ		ខ្លាចខាងតំបន់ខាងភូមិភាគអីទៀតណា មានភ្នាក់ងារគេតាមរកគន្លាណាក្លួយ ។

ដានីៈ		បាទ ។

ប៉ូចៈ		ហ្នឹងចឹងហើយរឿងមួយទៀតខ្ញុំចេះតែពិចារណាខ្លួនខ្ញុំ គេទៅប្រជុំនៅភ្នំពេញម្តងៗចឹងទៅមួយឆ្នាំម្តងចឹងទៅជួនកាលគេណែនាំ ថាបើយើងធ្វើសហករណ៍យើងស៊ីបាយរួមតើយើងដោះស្រាយបានទេ ហើយខាងមេបន្ទាប់មកថាយើងចេះតែដោះស្រាយបានខ្ញុំគិតក្នុងចិត្តខ្ញុំថាហូបបាយរួមវាមិនស្រួលទេ ខ្ញុំពិចារណាឃើញចឹង ឧទាហរណ៍ថាដូចជាខាងផ្នែកមជ្ឈឹមគេថាឥឡូវឲ្យហូបតាមក្រុមគ្រួសារសាចលញាតិជាចង្ក្រាមរបស់គេទៅ ប្រហែលជាស្រួល ហើយដល់មិនចឹងយកមករៀបទាំងភូមិៗចឹងខ្ញុំថាអើយទៅហើយអាហ្នឹងមួយមួយទៀតប្រជាជនមានកំហុសដោយប្រការនេះមួយប្រការនោះមួយ ហើយស្រាប់តែយើងហាឡើងមានវិធានការ ខាងចាត់តាំង ។

ដានីៈ		បាទ ។

ប៉ូចៈ ខាងដាក់ទោសដាក់កំហុស ឥឡូវខាងលើណែនាំមកមានវិធានការចាត់តាំងសម្លាប់ឬធ្វើយ៉ាងនេះធ្វើយ៉ាងនោះពីរ វាឃើញថាបើសម្លាប់មួយវាប៉ះពាល់ដល់ក្រុមគ្រួសារសាច់ញាតិមួយហ្នឹងមិនមែនតិចទេ យ៉ាងហោចណាស់ក៏រាប់សិបនាក់ដែរ អាហ្នឹងមួយ មួយទៀតបើយើងមានវិធានការចាត់តាំងកិរិតខ្ពស់យើងប្រៀបបាននិងសូត្រចំពាក់ឬមោងចំពាក់ យើងមិនអាចយកកន្ត្រៃយទៅកាត់ឬយកកាំបិតទៅកាត់សួរថាតើវារហែកប៉ុណ្ណា ។

ដានីៈ បាទ ។

ប៉ូចៈ ខ្ញុំថាគេណែនាំដូចជាច្បាស់ដែរ តែដល់ចុះមកដល់វាទៅជារឿងផ្សេងទៅវិញ ។

ដានីៈ ពេលចុះមកដល់រឿងផ្សេងហ្នឹងអ្នកណាជាអ្នកចាត់តាំង?

ប៉ូចៈ ចុះក្មួយដឹងហើយបើមកពីមជ្ឈិមមកវាមានភូមិភាគហ្នឹងហើយ ដល់ចឹងទៅវាពិបាកខ្ញុំមិនយល់ដល់ចឹង ដល់មែនទែនទៅរកតែវិធីខ្ពួនឲ្យបានរស់ ។

ដានីៈ ចុះអឺកាលជំនាន់ហ្នឹងក្នុងមួយឆ្នាំយើងត្រូវមកប្រជុំនៅភ្នំពេញម្តង?

ប៉ូចៈ បាទ ។

ដានីៈ មកប្រជុំហ្នឹងមកប្រជុំជាមួយពីណាគេ?

ប៉ូចៈ មកប្រជុំរួមចឹងទៅគ្រប់ស្រុកគ្រប់ខេត្តចឹងទៅ ។

ដានីៈ បាទ ។

ប៉ូចៈ ក្រោមអធិបតីរបស់ពីណាទៅ?

ដានីៈ នួន ជាចឹងទៅ ។

ប៉ូចៈ ចឹងពេលយើងទៅប្រជុំចឹងការងារយើងរាយការណ៍ឲ្យនួន ជាផ្ទាល់ឬក៏?

ដានីៈ អត់ទេ យើងរាយការណ៍តាមតំបន់ ខាងតំបន់គេទទួលទៅយកទៅឲ្យភាគទៅ ភាគយកបន្តទៅទៀតទៅ យើងគ្រាន់តែស្តាប់ទេ ។

ប៉ូចៈ បាទ ។

ដានីៈ ចឹងពេលដែលប្រជុំមានឃើញខាងភូមិភាគគេរាយការណ៍ទៅនួន ជាដែរឬអត់?

ប៉ូចៈ អត់សូវចាំទេក្មួយអេយវាច្រើនពេកណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ ចឹងណាស់ក្មួយ ។

ដានីៈ ចឹងអឺមានប្រសាសន៍មិញហ្នឹងមានគេធ្វើអីខុសចឹងអឺធ្លាប់ណែនាំដល់កូនចៅថ្នាក់ក្រោមៗឬឃើញគេធ្វើបុណ្យសពកាលសម័យហ្នឹងគេហាមឃាត់អីចឹងប្រាប់គេថា ឲ្យខ្ទប់ទ្វារឲ្យធ្វើឲ្យលឿនៗអីចឹង ចឹងកាលហ្នឹងអឺមាននៅចាំថាអឺធ្លាប់រាប់អានអ្នក១៧មេសាឬក៏ប្រជាជននៅក្នុងមូលដ្ឋានអឺរាប់អានអី អឺមាននៅចាំទេ?

ប៉ូចៈ ខ្ញុំវាច្រើនដែលវាមិនសូវចាំ ចេះតែជួយហូរហែរដែលក្នុយកាលជំនាន់ហ្នឹង ។

ដានីៈ ចឹងអ៊ីមាននៅចាំដែលកាលជំនាន់ហ្នឹង?

ប៉ូចៈ គិតវាមិនឃើញវាច្រើនពេកភ្លេចឈ្មោះណាក្នុយ ។

ដានីៈ ចឹងកាលនៅស្អាងអ៊ីមានធ្លាប់ជួយអ្នក១៧មេសាឬក៏ប្រជាជននៅមូលដ្ឋានអីទេ?

ប៉ូចៈ នៅស្អាងហ្នឹងតែដើរជួយប្រជាជនតាមស្រែតាមចំការហើយហ្នឹង ហើយប្រជាជន១៧មេសាខ្ញុំមិនដែលមានបញ្ហាអីជាមួយទេ អាហ្នឹងចំពោះផ្ទាល់ខ្លួនខ្ញុំណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ វាមិនចាំណាក្នុយមានច្រើនដែលណា ដូចជាករណីធ្វើទុកធ្វើបាបអីខ្ញុំលែងតែម្តងខ្ញុំមិនរាយការណ៍ហើយយកទោសកំហុសអី ។

ដានីៈ ចឹងកន្លែងហ្នឹងអ៊ីនៅចាំទេ ករណីដែលគេប្រុងធ្វើបាបហើយអ៊ីដែលវិញហ្នឹង?

ប៉ូចៈ ភ្លេចដែលណាក្នុយដល់សួរចឹងវគ្គអស់ហើយ ភ្លេចអស់ហើយ ។

ដានីៈ ចឹងករណីហ្នឹងវាកើតយ៉ាងម៉េចដែលអ៊ីថាមិនរាយការណ៍ឲ្យគេ?

ប៉ូចៈ វាមានកំហុសគ្នាស្រាល១ដូចជាខ្ញុំបានជំរាបចឹង គ្រាន់តែលួចនេះលួចនោះយកទៅហូបហ្នឹងណាស់ ។

ដានីៈ បាទ ។

ប៉ូចៈ ដូចជាដកដំឡូងដូចជាគ្នាចុះទៅធ្វើពលកម្ម....

## ***ផ្នែកខាងបី***

ដានីៈ ចឹងដូចជាលួចដំឡូងឬការងារធ្វើពលកម្មហ្នឹងតើអ៊ីចុះទៅផ្ទាល់ឬមួយគេរាយការណ៍មកឲ្យអ៊ី?

ប៉ូចៈ អត់ទេ ខ្ញុំចុះភាគច្រើនខ្ញុំចុះទៅតែម្តង ។

ដានីៈ ចុះទៅតាមការដ្ឋាន?

ប៉ូចៈ បាទ!ដូចជាការដ្ឋានជីកប្រឡាយនៅកន្លែងកំប៉ើយនៅរាយណ៍នេះឯង ដូចជាកងចល័តនេះរាប់ម៉ឺនខ្ញុំចុះទៅជាប់ ពេលឃើញក្មេង១វានឹកផ្ទះនឹកសំបែងនឹកម៉ែនឹកឪខ្ញុំតែងតែកំណត់ពេលខ្ញុំថាឥឡូវយើងយ៉ាងយូរ១០ថ្ងៃយើងត្រូវទៅលេងផ្ទះ ហើយហ្នឹងមួយហើយទៀតខ្ញុំក៏បានទៅស្រុកទៅផ្ទះសំបែងខ្ញុំទៅ ខ្ញុំក៏បានទៅឃើញការព្រាត់ប្រាស់កូនចៅខ្ញុំក្នុយខ្ញុំអី១តែងតែគេប្រមូលទៅការដ្ឋាន ដល់ចឹងទៅខ្ញុំត្រឡប់មកវិញតែងតែនឹកឃើញថាផ្ទាល់ខ្លួនយើងប៉ុណ្ណឹង យើងចេះអាណិតអាសូរស្រាប់យើងឈាមយើងដល់ពេលកូនចៅគេរាប់ពាន់

រាប់ម៉ឺនដល់មកធ្វើការដ្ឋានឲ្យគ្នាដេកត្រាំត្រែងហាលសន្សើម ហាលកៅរាប់ខែនៅហ្នឹងអាហ្នឹង មិនត្រូវទេអាហ្នឹងខ្ញុំមានធម៌អនុគ្រោះសណ្ដោះ ឲ្យបងប្អូនទៅលេងផ្ទះលេងសម្បែងជាបន្តបន្ទាប់អាហ្នឹងខ្ញុំនិយាយពីចំណុចខ្ញុំបានជួយ ។

ដានីៈ បាទ ។

ប៉ូចៈ មានការខុសឆ្គងត្រឹមសីលធម៌រឿងបុរសនារីខ្ញុំមិនដែលធ្វើបាបទេ ខ្ញុំគ្រាន់តែនែនាំ ។

ដានីៈ ចឹងករណីហ្នឹងអឹមានដែលចាំទេ ករណីដែលមានខុសសីលធម៌ករណីហ្នឹងអឹមានដែលចាត់ការផ្ទាល់ដៃដែរ?

ប៉ូចៈ នៅពេលប្រជុំអីហ្នឹងក្មួយគេបានរាយការណ៍ពីខាងសហករណ៍អីចឹងទៅ ខ្ញុំតែងតែមានយោបល់ពិចារណាចឹង ថាឥឡូវយើងមិនត្រូវតឹងរឹងដាច់អហាំងការទេ ចំពោះបុរសនិងនារីបើយើងតឹងពេកឃើញថាមិនបានទេ ខ្ញុំមានតែប៉ុណ្ណឹងទេក្មួយ ។

ដានីៈ បាទ ។

ប៉ូចៈ ស្អីៗទៀតមានខាងគ្រូ កាលហ្នឹងគេជ្រើសរើសសមាសភាពគ្រូ ប្រមូលគ្រូហ្នឹងមករៀនសូត្រហើយចឹងទៅឲ្យគាត់ទៅវិញ ។

ដានីៈ បាទ ។

ប៉ូចៈ អាហ្នឹងវាចឹង ពេលខ្លះគេប្រមូល ។

ដានីៈ បាទ! ចឹងអឹផ្ទាល់តែម្ដងអឹមានទៅពន្យល់ប្រជាជនថ្មីឬប្រជាជននៅតាមមូលដ្ឋានហ្នឹង អឹមានទៅពន្យល់ប្រាប់គាត់ថា បងប្អូនឬអឹពូមីងណាហ្នឹងថាយើងធ្វើយ៉ាងម៉េចឲ្យបានសុខសាន្តឲ្យរួចផុតមិនឲ្យមានទោសពៃរ៍អីអឹធ្លាប់មានពន្យល់ប្រាប់ពួកគាត់ដែលឬអត់?

ប៉ូចៈ មានដែលក្មួយ តែខ្ញុំមិនបានចាំរឿងចឹងខ្ញុំមាននិយាយជាហូរហែរដែរ ។

ដានីៈ មាននិយាយថាយ៉ាងម៉េច?

ប៉ូចៈ និយាយថាយើងដឹងថាគ្នាជាអ្នក១៧មេសាហើយ ចេះតែមានកំហុសចេះតែមានរឿងរ៉ាវទេ យើងធ្វើម៉េចខំធ្វើអំពើល្អគេហៅថាមាត់យើងសំដីយើង ទោះបីយើងអីទោះបីយើងមិនធ្វើអីយើងនៅឲ្យស្ងៀម យ៉េងខំធ្វើការងារតាមកំលាំងដែលយើងមានទៅ ខ្ញុំថាចឹងណាស់ ។

ដានីៈ ចឹងអឹនិយាយចឹងជាសាធារណៈឬអឹនិយាយជាសម្ងាត់?

ប៉ូចៈ ខ្ញុំនិយាយសាធារណៈក៏មាននិយាយជាសម្ងាត់ក៏មាន ឯនិយាយជាសាធារណៈហ្នឹងខ្ញុំប្រជុំខ្ញុំមិនសមបើនិយាយទេ កាលជំនាន់នោះ ពេលអនុលេខាខ្ញុំនៅស្រុកបារាយណ៍ហ្នឹង ពេលគេឡើងធ្វើមេទិញប្រជុំទៅគេប្រកាសយ៉ាងម៉េច? ប្រកាសថាអ្នកណាដែលបំផ្លិចបំផ្លាញសហករណ៍ ធ្វើឲ្យបាក់នង្គ័លធ្វើឲ្យបាក់រនាស់ធ្វើឲ្យខូចខាតរទេះគោសប់បែបសប់យ៉ាង

អាហ្នឹងសុទ្ធតែខ្លាំងហើយ ហើយអ្នកមិនទៅធ្វើពលកម្មសុទ្ធតែខ្លាំង ដល់ចឹងខ្ញុំទ្រាំមិនបាន ខ្ញុំហៅប្រជាជនមួយឃុំមានប្រជាជនប្រហែលជា៥០០ទៅ៦០០នាក់ ខ្ញុំថាឥឡូវរឿង ចោរវាលួចដំឡូវវាលួចដាំបាយស៊ីគឺមូលហេតុមកពីយើងក្រ មូលហេតុមកពីអត់បាយ ព្រោះដោះស្រាយបាយឲ្យគេមិនបាន អាហ្នឹងមួយយើងត្រូវធ្វើចឹង ហើយបញ្ហាមួយ ទៀតរឿងភ្នូរបាក់ទន្លប់ហើយយើងចេះតែថាខ្លាំងបំផ្លិចបំផ្លាញអាហ្នឹងក៏វាមិនត្រឹមត្រូវ ធម្មតាភ្នូរស្រែវាតែងតែមានគល់មានព្រៃអីហើយយើងមើលវាមិនឃើញដល់ប៉ះទៅវាមិន បាក់ មួយផ្នែកទៀតខ្ញុំថាឥឡូវដើម្បីជីវភាពយើងបានសមរម្យមានហូបមានចុក ឥឡូវ យើងធ្វើឯកជនផងយើងធ្វើរួមផង ឯកជនត្រង់ណា ឧទាហរណ៍ដូចជាដំណាំជុំវិញផ្ទះ ដូច ជាពោត ដូចជាដំឡូវ៣០០ទៅ៤០០គុម្ពមេមាន់មួយឬពីរទៅយើងហូបតាមគ្រួសារទៅ យើងដោះស្រាយទៅយើងហូបបាយនៅតាមសហករណ៍មិនឆ្អែតយើងមកហូបពោតដំឡូវ នៅតាមផ្ទះយើងក៏បាន ហើយយើងហូបមិនអស់យើងមានសណ្ដានចិត្តយើងយកទៅឲ្យ សហករណ៍យើង យើងចង់ឲ្យសហករណ៍យើងមានហូបយើងយកឲ្យសហករណ៍ខ្លះទៅ ដល់ ពេលហ្នឹងគាត់បានដាំបានចិញ្ចឹមអីទៅ ចឹងពោតហ្នឹងមិនត្រឹមតែបានហូបខ្លួនគាត់ទេ សហ ករណ៍ក៏បានហូបដែរ រហូតគាត់បានយកមកឲ្យខ្ញុំដល់សាលាស្រុកទៀត ។

ដានី: ចឹងអ៊ីបើចឹងអ៊ីមិនមានបញ្ហាជាមួយអនុលេខាសមាជិកជាមួយគ្នា ព្រោះពួកគាត់ថាអ្នកបាក់ ទន្លប់អ្នកលួចដំឡូងសុទ្ធតែខ្លាំងហើយអ៊ីនិយាយចឹងវាមិនមានបញ្ហាជាមួយគ្នាឬយ៉ាងម៉េច ?

ប៉ូច: អត់អីទេ តែពេលហ្នឹងគេខឹងខ្ញុំដែរ តែពេលហ្នឹងខ្ញុំមានគំនិតមួយថា ខ្ញុំសុខចិត្តឲ្យគេខឹងតែ ធ្វើម៉េចឲ្យតែប្រជាជនបានហូបដូចយើងដែរ អាហ្នឹងជាគំនិតរបស់ខ្ញុំទេ គេខឹងគេរាយ ការណ៍ទៅខាងលើដែលហ្នឹង តែទៅវាមិនរួច ព្រោះលើទៀតមិនមានត្រឹមភាគឯណា ថា កន្លែងណាដោះស្រាយជីវភាពប្រជាជនបានគឺកន្លែងហ្នឹងល្អ ខ្ញុំស្ដាប់ពាក្យហ្នឹងមក ។

ដានី: ខ្ញុំដូចជាមិនទាន់យល់កន្លែងហ្នឹងច្បាស់ ដូចថាគាត់លួចដំឡូវអីចឹងយើងចាត់ទុកថាខ្លាំងចឹង យើងសម្លាប់ពួកគាត់ឬក៏យើងបញ្ជូនពួកគាត់ទៅខាងតំបន់ឬភាគឬមួយយើងអាចកាត់ ទោសពួកគាត់ត្រឹមស្រុកត្រឹមឃុំត្រឹមសហករណ៍សម្លាប់ពួកគាត់?

ប៉ូច: កំរិតត្រឹមប៉ុណ្ណឹងយើងសម្រេចត្រឹមអប់រំណែនាំ មិនមែនដល់ទៅមានទោសជាប់គុកជាប់ច្រ វ៉ាក់ទេ វាមានកំរិតទោសរបស់គេដែលកុំនិយាយណាស់ ។

ដានី: បាទ ។

ប៉ូច: អាហ្នឹងចឹង ។

ដានី: ចឹងកំរិតចឹងយើងថាអប់រំតែតាមការដាក់ស្ដែងវាយ៉ាងម៉េចដែរ?

ប៉ូចៈ ដាក់ស្តែងភាគតិចដែលមានទោសដែលត្រូវឃុំឃាំងណាក្មួយ ដល់គំរិតយើងអប់រំពីរងងបី ដងងអីទៅមិនបានយើងទប់មិនឈ្នះអីទៅជូនកាលយើងរាយការណ៍ទៅលើ ។

ដានី៖ ចឹងដូចអ៊ីមានប្រសាសន៍ថា នៅការដ្ឋានធំមានយុវជនយុវនារីរាប់ម៉ឺននាក់ធ្វើការ ដូចជាអ៊ីចុះទៅផ្ទះចឹងឃើញថាពួកគាត់មានបញ្ហាដូចជាអវត្តមានឬដោយសារហូបមិនឆ្អែតមានលួចដំឡូវហូបអីចឹង អ៊ីថាលាក់មិនរាយការណ៍ទៅលើបានន័យថា បញ្ហាចឹងៗត្រូវរាការណ៍ទៅលើឬអ៊ីមានសិទ្ធសម្រេចថាត្រូវពិន័យយុវជនយុវនារីបានដែរ?

ប៉ូចៈ យើងសម្រេចបានអត់មានអីទេ ដូចអ៊ីបានជំរាបក្មួយខាងលើចឹង ។

ដានី៖ បាទ ។

ប៉ូចៈ ឧទាហរណ៍ថាជីកប្រឡាយខាងភាគឬខាងតំបន់គេកំណត់ឲ្យយើងថាប៉ុន្មានខែ ។

ដានី៖ បាទ ។

ប៉ូចៈ ឧទាហរណ៍ថាបីខែ ហើយយើងប៉ាន់ស្មានថាការងារយើងថាប៉ុន្មានខែត្រូវរួច យើងយើងទៅមិនហួសផែនការ ។

ដានី៖ បាទ ។

ប៉ូចៈ ត្រឹមបីខែហ្នឹងហើយអាហ្នឹងយ៉េង ក្នុង១០ថ្ងៃ ក្នុងថ្ងៃ២០ថ្ងៃ៣០ហ្នឹងគឺយើងគឺយើងមានសិទ្ធដូគ្នាឲ្យបងប្អូនទៅលេងផ្ទះបាន ដាក់វេនគ្នាបីថ្ងៃឬប្រាំថ្ងៃចឹងណាស់ក្មួយ ។

ដានី៖ បាទ! កាលជំនាន់ហ្នឹងតាំងពីអ៊ីនៅស្អាង នៅតាំងគោកនៅបារាយណ៍ហ្នឹងអ៊ីមានធ្លាប់ជួយប្រជាជនឬប្រជាជនមូលដ្ឋានគាត់ជាប់ទោសជាប់គុកជាបលអីអ៊ីមានដែលជួយសម្រួលឲ្យពួកគាត់បានរួចខ្លួនឬក៏ត្រូវគេធ្វើទារុណកម្មហើយអ៊ីត្រូវឃាត់កុំឲ្យគេធ្វើបាបអ៊ីមានករណីហ្នឹងដែលឬអត់?

ប៉ូចៈ ខ្ញុំមានដែលក្មួយតែដូចខ្ញុំថាចឹង វាភ្លេចកន្លែងបាត់ហើយព្រោះនៅវាច្រើនកន្លែងពេក ។

ដានី៖ ចឹងអ៊ីមានចាំកន្លែងទេ ចឹងអ៊ីមាននៅចាំព្រឹត្តិការណ៍រឿងរ៉ាវយ៉ាងម៉េចអ៊ីមាននៅចាំទេ?

ប៉ូចៈ មាននៅខាងត្បូងអង្គស្អួលនោះម្តង ឈ្មោះមុំ ។

ដានី៖ ឈ្មោះមុំហ្នឹងគាត់ជាស្អីគេ?

ប៉ូចៈ គាត់ជាប្រជាជនដែលតែគាត់មានការរាប់អានជាមួយខ្ញុំ កាលនោះគេចាប់វ៉ៃចងហើយខ្ញុំបានទៅធានាដោះលែងវិញ ។

ដានី៖ ពីណាជាអ្នកចាប់?

ប៉ូចៈ ខាងស្រុក ។

ដានី៖ ខាងស្រុកណា?

ប៉ូចៈ ខាងស្រុកកណ្តាលស្ទឹង កាលនោះនៅម៉ាចំហៀងតស៊ូ ។

ដានី៖ គេចោទគាត់ថាយ៉ាងម៉េច?

ប៉ូច៖ គេចោទគាត់ថាខ្មាំងមកស៊ើការណ៍អីនៅមូលដ្ឋាន កាលនោះតំបន់គាត់នៅខាងក្នុង នៅឃុំកន្ទោកហ្នឹងតែក្មេចភូមិ ។

ដានី៖ ហើយគាត់ចូលទៅណា?

ប៉ូច៖ គាត់មកកាលហ្នឹងមានការចែកតំបន់គ្នា កាលយើងវាយំព័តភ្នំពេញហ្នឹង កាលជំនាន់នោះការហ្នឹងគាត់មករកបងប្អូនមិនដឹងទេ ពេលគាត់មកវាមានព្រឹត្តិការណ៍វ៉ៃគ្នាចចឹងណាស់ ។

ដានី៖ បាទ ។

ប៉ូច៖ ដល់ចឹងទៅគាត់មកត្រូវគេចាប់វ៉ៃស្នូរចម្លើយ ។

ដានី៖ ខាងណាជាអ្នកចាប់?

ប៉ូច៖ ខាងអកគស៊ូខាងយើងហ្នឹងនោះណាស់ ហើយខ្ញុំក៏នៅឃុំកន្ទោកហ្នឹងដែលហ្នឹង ។

ដានី៖ ចឹងអឹជាអ្នកទទួលខុសត្រូវឃុំកន្ទោកហ្នឹង?

ប៉ូច៖ បាទ!នៅឃុំកន្ទោកហ្នឹង ។

ដានី៖ ហើយខាងស្រុកគេមកចាប់ប្រជាជនរបស់អឹ?

ប៉ូច៖ បាទ ។

ដានី៖ ចឹងមានគេធ្វើទារុណកម្មថាឈ្មោះមុំអ៊ីចឹង គេចោទថាគាត់មកយកការណ៍ឲ្យទាហានខាងលន់នល់អ៊ីចឹង?

ប៉ូច៖ បាទ ។

ដានី៖ ហើយអឹទៅធានា?

ប៉ូច៖ បាទ!ហើយកាលហ្នឹងមានក្មេងមួយឈ្មោះខ្ញុំភ្លេចហើយក្មេងស្រី ។

ដានី៖ ហ្នឹងប្រហែលជាឆ្នាំណា?

ប៉ូច៖ ប្រហែលជាឆ្នាំ១៩៧៤ ។

ដានី៖ ចឹងចន្លោះឆ្នាំ១៩៧៥ដល់៧៩ អឹមានដែលបានជួយដែលប្អូនអត់ដូចជាកាលនៅស្អាងអី អឹមានដែលបានជួយដែលប្អូនអត់?

ប៉ូច៖ ខ្ញុំមានជួយហូរហែរដែលក្មួយតែមិនបានចាំឈ្មោះដែរ ។

ដានី៖ ចឹងកាលហ្នឹងអឹជួយពួកគាត់យ៉ាងម៉េចខ្លះ?

ប៉ូច៖ កាលហ្នឹងវាភ្លេចអស់ហើយក្មួយ ។

ដានី៖ ចុះកាលជំនាន់បីឆ្នាំហ្នឹង អឹមានធ្លាប់ឲ្យអង្ករឲ្យចំណីអីអឹមានធ្លាប់បានឲ្យដែរ?

ប៉ូច៖ មានធ្លាប់ដែរ ។

ដានី៖ ឲ្យទៅពីណា?

ប៉ូចៈ ទេមិនបានចាំទេ ខ្ញុំដើរទៅឃើញគាត់អត់មានអង្ករអីហ្នឹងខ្ញុំឲ្យនិរសាយកអង្ករទៅឲ្យគាត់ហូបដែរ ។

ដានីៈ នៅណាហ្នឹង ហើយឆ្នាំណាដែរ?

ប៉ូចៈ ឆ្នាំដូចជាឆ្នាំ៧៧-៧៨ហ្នឹង ។

ដានីៈ កាលអ៊ំនៅតាំងគោកឬនៅបារាយណ៍ហ្នឹង?

ប៉ូចៈ ស្រុកនេះទេ ដែលខ្ញុំនៅកាលឆ្នាំ៧៧-៧៨ហ្នឹង ។

ដានីៈ ចឹងកាលអ៊ំធ្វើជាលេខាស្រុកអីចឹងខាងតំបន់មានបញ្ជាមកអ៊ំថាត្រូវយកអ្នកនេះទៅអ្នកនោះទៅគេមានដែលបញ្ជាមកចឹងទេ?

ប៉ូចៈ ខ្ញុំមានការតវ៉ាដូចជាកម្មាភិបាលចាស់ៗជំនាន់នោះ ខាងស្រុកបារាយណ៍ហ្នឹងក៏ដោយថ្ងៃមួយមកសំឡុតខ្ញុំថា នៅក្នុងស្រុកមិត្តឯងហ្នឹងដូចជាមិនឃើញដកហូតអ្នកដែលជាកម្មាភិបាលចាស់ៗ ឲ្យតែកម្មាភិបាលចាស់ត្រូវតែដកទាំងអស់ហើយមិត្តឯងយ៉ាងម៉េចបានជាមិនដក ខ្ញុំថាដកយ៉ាងម៉េចបើគ្នាខំដឹកនាំប្រជាជនហើយមិនដែលប្រកាន់ភាពប្រឆាំងឬក៏ថ្នាំងថ្នាក់ជាមួយសោះខ្ញុំរកនឹកដកមិនឃើញខ្ញុំថាចឹង បីបួនប្រាំសារ ។

ដានីៈ បាទ ។

ប៉ូចៈ ខ្ញុំនឹកអាណិតខ្ញុំស្តាយខ្ញុំឃើញថាដូចជាខ្ញុំជំរាបខាងដើមចឹងគេប្រាប់ពីលើមកថាចំពោះអ្នកណាដែលប្រឆាំងពិតប្រាកដ ហើយបើអត់មានសកម្មភាពអីផងហើយចេះតែឲ្យចុចឈ្មោះដកៗខ្ញុំនឹកក្នុងចិត្តថាអស់ហើយ ខ្ញុំថាអត់មានទេស្រុកខ្ញុំមិនមានទេ ហើយបើមិនជឿទេ ខ្ញុំឲ្យសួរអនុលេខាសួរសមាជិកអីចឹង ដល់ក្រោយមកគេយកអនុលេខាខ្ញុំទៅបាត់ ។

ដានីៈ អនុលេខាឈ្មោះអី?

ប៉ូចៈ ឈ្មោះឆន ។

ដានីៈ អនុលេខានៅណា?

ប៉ូចៈ ហ្នឹងស្រុកកំណើតគាត់នៅបារាយណ៍ដែរ ។

ដានីៈ គាត់ជាអនុលេខានៅណា?

ប៉ូចៈ នៅស្រុកតាំងគោក ដកឆនហើយដកដេនមួយទៀត ខ្ញុំឡើងប្រឹងខ្លួនបណ្តោយខ្ញុំយ៉ាងដែរ ។

ដានីៈ មានដឹងថាគេដកយកទៅណា?

ប៉ូចៈ មានដឹងថាគេយកទៅណាទេ តែគេថាយកទៅតំបន់ ។

ដានីៈ កាលហ្នឹងគណៈតំបន់ឈ្មោះអីគេ?

ប៉ូចៈ គាត់នៅស្រុកបារាយណ៍ហ្នឹងដែរ គាត់ឈ្មោះអឿនតែគាត់ស្លាប់បាត់ហើយ ។

ដានី៖ អឿន ប្អូនថ្លៃតា ពកហ្នឹង?

ប៉ូច៖ បាទ! ដល់ខ្ញុំគិតថាចឹងអស់ទៀតហើយ ពេលយកពីរអ្នកហ្នឹងបាត់ទៅហើយផ្លាស់ខ្ញុំឲ្យមកបារាយណ៍ ក៏ដកប្រធានស្រុកបារាយណ៍ចេញទៀតទៅ ខ្ញុំគិតថាមិនដឹងជាថ្ងៃណាទេ ដេករង់ចាំតែថ្ងៃបានរួចមួយថ្ងៃៗសឹកបុណ្យកោបានរួចមួយខែៗ កាលហ្នឹងចេញទៅអស់រលីងស្ងួរទៅដាក់នេះមកថ្មីដាក់អានោះមកថ្មីចប់ ។

ដានី៖ ចឹងអ៊ំមានដឹងថាមូលហេតុអីបានជាគេចេះតែដកចឹង?

ប៉ូច៖ កាលជំនាន់នោះគេចោទថាខ្សែលោកយ៉ា ខ្សែលោកធុចអីចឹងទៅណាស់ ។

ដានី៖ បាទ! ។

បច៖ កាលហ្នឹងសមាជិកបក្សទាំងអស់គ្នាមិនដឹងអាណាជាអ្នកណាទេ ជំនាន់ហ្នឹង ខ្ញុំមិនថាជាថ្ងៃណាថ្ងៃណីទេ ខ្ញុំសាបមាត់សាបកហើយ ។

ដានី៖ អ៊ំអត់មានធ្លាប់អានបងប្អូនធម៌ជាមួយប្រជាជនឬអ្នក១៧មេសាអីទេ?

ប៉ូច៖ ខ្ញុំមានធ្លាប់អានញាតិច្រើនណាស់ តែខ្ញុំភ្លេចដូចខ្ញុំបានប្រាប់ក្មួយរួចមកហើយ ។

ដានី៖ ចុះក្រោយទៀតមកអ៊ំមានធ្លាប់រាប់អានអីទេ ដូចជាបែកឆ្នាំ៧៩រហូតមកដល់ឥឡូវហ្នឹងប្រជាជនដែលអ៊ំធ្លាប់រាប់អានអីហ្នឹងមកដល់ឥឡូវហ្នឹងមានធ្លាប់មករាប់អានអ៊ំទៀតទេ?

ប៉ូច៖ មានដែលអ្នកស្រុកគាត់តែងតែមកលេងដូចជាបងប្អូនម៉ែឪប្រជាជននៅនេះ ជួនគាត់មកចឹងគាត់ឆ្លៀតមកលេងចឹងទៅ ។

ដានី៖ នៅណា?

ប៉ូច៖ នៅបារាយណ៍ក៏មាននៅតាំងគោកក៏មាន ។

ដានី៖ មានមកលេងនៅហ្នឹងដែរ?

ប៉ូច៖ បាទ ។

ដានី៖ ចឹងមានពីណាខ្លះអ៊ំអាចលើកជាឧទាហរណ៍ពីរបីនាក់បានទេ?

ប៉ូច៖ មានឈ្មោះ តា អ៊ូ យាយអីទេភ្លេចហើយ តា កង ។

ដានី៖ មកលេងពេលឥឡូវៗហ្នឹងដែរ?

ប៉ូច៖ មកលេងជាងមួយឆ្នាំហើយ ជួនកាលមកលេងរកបងរកប្អូនគាត់ទៅ ។

ដានី៖ ពេលក្រោយវៀតណាមចូលមកខែមករាឆ្នាំ១៩៧៩ហ្នឹងពេលហ្នឹងយ៉ាងម៉េចទៀតទៅ?

ប៉ូច៖ ពេលហ្នឹងនៅក្នុងព្រៃហើយកាលហ្នឹង ហើយមិនដឹងទៅណាក៏នាំគ្នារត់គស៊ូក្នុងព្រៃទៅ ។

ដានី៖ មកនៅកន្លែងណា?

ប៉ូច៖ មកនៅក្នុងព្រៃបុសពក ។

ដានី៖ បុសពកហ្នឹងនៅខាងណា?

ប៉ូចៈ បុសពកហ្នឹងនៅបារាយណ៍ខាងលើ ។

ដានីៈ ហើយយ៉ាងម៉េចទៀត?

ប៉ូចៈ ទៅនៅនាំកូននាំចៅក្រុមគ្រួសារបងប្អូនមួយចំនួនហ្នឹងទៅ បេះតែនៅបានប៉ុន្មានខែទេប្រពន្ធហ្នឹងស្លាប់ទៀតទៅ ។

ដានីៈ ប្រពន្ធទី២ឈ្មោះអី?

ប៉ូចៈ ឈ្មោះសល់ ។

ដានីៈ ជាអ្នកស្រុកណា?

ប៉ូចៈ នៅស្រុកកណ្តាលស្ទឹង ។

ដានីៈ ប្រពន្ធទី២រៀបការឆ្នាំណា?

ប៉ូចៈ ខ្ញុំរៀបឆ្នាំ៧៦ហើយ ។

ដានីៈ អ៊ំរៀបការនៅណា?

ប៉ូចៈ រៀបនៅស្រុកស្អាង ។

ដានីៈ អ៊ំមានកូនប៉ុន្មានទៀត?

ប៉ូចៈ បានកូនពីរស្លាប់ទៅ ។

ដានីៈ ស្លាប់ជំនាន់ណា?

ប៉ូចៈ ស្លាប់ជំនាន់៧៩ហ្នឹង ។

ដានីៈ ចឹងនៅពេលតស៊ូឆ្នាំ៧៩ហ្នឹងប្រពន្ធពូស្លាប់បាត់ទៅ?

ប៉ូចៈ បាទ ។

ដានីៈ ស្លាប់ដោយសារអីគេ?

ប៉ូចៈ ស្លាប់ដោយសារជំងឺ ។

ដានីៈ ឆ្នាំណា?

ប៉ូចៈ ស្លាប់៧៩ ។

ដាន់ៈ ចុះកូនស្លាប់ឆ្នាំណា?

ប៉ូចៈ ស្លាប់ឆ្នាំ៧៩ដូចគ្នាគ្រាន់តែខុសខែ ។

ដានីៈ ស្លាប់ដោយសារជំងឺគ្រុនចាញ់?

ប៉ូចៈ បាទ ។

ដានីៈ ហើយយ៉ាងម៉េចទៀតទៅ?

ប៉ូចៈ គេបេះតែឲ្យយើងខំតស៊ូចឹងទៅ ។

ដានីៈ ពេលមកតស៊ូអ៊ំមកទទួលខាងអីវិញទៅ?

ប៉ូចៈ ខ្ញុំមកទទួលកំលាំងស្រុកមួយចំនួនដែលបងប្អូនមកជាមួយហ្នឹងណាស់ ចូលមកឃ្មឺឃ្មាហ្នឹងទៅ ចូលមកដល់ខ្ញុំនិយាយថាបងប្អូនណាដែលទ្រាំបាន ក៏នៅទៅបើបងប្អូនណាទ្រាំមិនបានក៏អញ្ជើញទៅផ្ទះទៅសំបែងទៅរកម៉ែឪទៅ ស្រុកណាស្រុកហ្នឹងហើយបងប្អូនណានៅតស៊ូទៀត ក៏តមកខ្ញុំអត់មានបង្ខំទេ ។

ដានីៈ ពេលដែលអ៊ំមកនៅក្នុងព្រៃហ្នឹងអ៊ំនៅជាគណៈស្រុកដដែល?

ប៉ូចៈ បាទ!គណៈស្រុកដដែល ដល់ក្រោយមកឆ្នាំ៨០ គេចាត់តាំងឲ្យខំមកគ្រប់គ្រងទ័ពមួយចំនួនទ័ពដែលដាច់ដោចមេកើយ ។

ដានីៈ អាហ្នឹងគេហៅអីវិញទៅ?

ប៉ូចៈ កាលគ្រាន់តែទទួលមុខសញ្ញាកំពង់ចាមកំពង់ធំចឹងទៅណាស់ ។

ដានីៈ ជាបញ្ជាការ?

ប៉ូចៈ បាទ! បានតែប៉ុន្មានខែទេ ក៏តា ពកគាត់ចុះទៅទទួលក្តាប់នៅសមរភូមិហ្នឹង ខ្ញុំជាសមាជិកគាត់ចឹងមក ។

ដានីៈ អនុរបស់តា ពក?

ប៉ូចៈ ខ្ញុំជាសមាជិក អនុតា ពិចដាង ដល់ឆ្នាំ៨៧ខ្ញុំដាច់ជើង ។

ដានីៈ ជើងអ៊ំពិការដោយសារអីគេ?

ប៉ូចៈ ដោយសារត្រូវមីុន ។

ដានីៈ មីុនហ្នឹងជាន់យ៉ាងម៉េច?

ប៉ូចៈ មីុនហ្នឹងជាន់ដោយសារតែធ្វើដំណើរទៅសមរភូមិ ។

ដានីៈ សមរភូមិកន្លែងណាទៅ?

ប៉ូចៈ សមរភូមិនៅអូរគ្រង ។

ដានីៈ អូរគ្រងហ្នឹងនៅខេត្តណាទៅ?

ប៉ូចៈ នៅខាងខេត្តសៀមរាប ខាងស្រុកជីក្រែង ។

ដានីៈ មីុនហ្នឹងជាមីុនខាងណាជាអ្នកដាក់?

ប៉ូចៈ មីុនហ្នឹងមិនដឹងជាខាងណាដាក់ទេ កាលហ្នឹងដាក់ច្រើនគ្នា ។

ដានីៈ ចឹងដល់អ៊ំពិការជើងចឹងយ៉ាងម៉េចទៀតទៅ?

ប៉ូចៈ ដល់ខ្ញុំពិការជើងខ្ញុំត្រូវដកមកខាងក្រោយវិញទៅ ។

ដានីៈ នៅខាងក្រោយហ្នឹងកន្លែងណា?

ប៉ូចៈ នៅព្រំដែននៅជំរំអូរគ្រាវ ហៅគងអំពិល ។

ដានីៈ នៅហ្នឹងអ៊ំទទួលអគ្គភាពជំរំហ្នឹងឬយ៉ាងម៉េច?

ប៉ូច: អត់ទេ ខ្ញុំនៅហ្នឹងទទួលអន្តភាពគ្រួសារកងទ័ពមីង៧ហ្នឹង គ្រួសារកងទ័ព៤១៧របស់តាពកហ្នឹង ។

ដានី: អាហ្នឹងកងពល?

ប៉ូច: បាទ ។

ដានី: ចឹងពេលអ៊ីមកនៅជំរំហ្នឹងអ៊ីមានធ្លាប់ជួបជនភាសខ្លួនទៅពីខាងក្នុងអីអ៊ីមានបានជួបទេ?

ប៉ូច: មានជួបដែរ ច្រើនណាស់កាលហ្នឹងនៅជំរំ ។

ដានី: ចឹងអ៊ីមានធ្លាប់ជួយពួកគាត់ឲ្យបានភាសខ្លួនទៅក្រៅប្រទេសអីទេ អ៊ីមានធ្លាប់បានជួយដែរឬទេ?

ប៉ូច: មានតែរកនឹកមិនឃើញទេក្មួយ ។

## កាសែ្សតទី២ខាងអេ

ដានី: ចឹងអ៊ីកាលអ៊ីតស៊ូនៅក្នុងព្រៃហ្នឹងមានដែលជួបប្រជាជនដែលរត់គេចមកពីខាងក្នុងហើយមានជួបតាមផ្លូវអីឬមានឃើញពួកគាត់ត្រូវរបួសអីមានដែលទេ?

ប៉ូច: មានធ្លាប់ដែលណាក្មួយតែវាមិនចាំច្រើនកន្លែងពេក ។

ដានី: ចឹងអ៊ីធ្វើការប៉ាន់ស្មានមើលថាអ៊ីមានជួយប៉ុន្មានដងហើយមានគ្នាប៉ុន្មាននាក់ដែរ?

ប៉ូច: ធ្លាប់ជួយដែលតែមិនដឹងត្រង់ណាខ្លះទេ ចេះតែមានជួយតែរកនឹកមិនឃើញ ។

ដានី: ចឹងកាលជួយហ្នឹងមានមូលហេតុអីបានជាអ៊ីជួយពួកគាត់ហ្នឹង?

ប៉ូច: ខ្ញុំមានមូលហេតុខ្ញុំជួយនេះខ្ញុំពិនិត្យឃើញការខុសឆ្គងរបស់គាត់មើលទៅថាដូចជាមិនមានអីដែលវាធំដុំហ្នឹងម្យ៉ាង ម្យ៉ាងវិញទៀតដោយខ្ញុំមានសីលធម៌មួយដែលខ្ញុំមានការពិចារណាមិនថារូបគេមិនថារូបខ្ញុំមានកង្វះខាតផ្ទាល់ខ្លួនហើយ ឬមានទុក្ខទោសនៅក្នុងខ្លួនហើយហ្នឹងបើកាលណាយើងជួយគេទៅគង់មានថ្ងៃណាមួយគេជួយយើងវិញ បើយើងធ្វើអំពើល្អគឺវាតែងតែផ្តល់ផលល្អមកវិញដែលក្មួយ អាហ្នឹងចឹងអានេះជាសីលធម៌ក្នុងការរស់នៅ ដូចជាខ្ញុំនិយាយខាងដើមចឹងឪពុកខ្ញុំម្តាយខ្ញុំគាត់តែងតែមានសីលមានទានមានធម៌មានអារ្យក្នុងខ្លួនគាត់តែងតែពិចារណានិងអប់រំកូន ឲ្យកូនសុភាពរាបសារមិនឲ្យកូនប៉ះដៃយកដៃប៉ះជើងយកជើងតែងតែសណ្តោះអនុគ្រោះតែងតែអាណិតអាសូរ្យ បាទអាហ្នឹងគឺចឹង ។

ដានី: បាទ ។

ប៉ូច: អាហ្នឹងជាប្រពៃណីខ្លួនខ្ញុំខំធ្វើកន្លងមកចឹងទោះបីសម័យណាក៏ដូចជាសម័យណាដែរ ។

ដានី: បាទ ។

ប៉ូច: ខ្ញុំយល់ឃើញថា បើយើងមិនបត់ឲ្យទាន់សភាពការណ៍មួយៗ ក៏យើងតែងតែវិនាសខ្លួនដែរ ។

ដានីៈ បាទ ។

ប៉ូចៈ ការពិតខ្ញុំផ្ទាល់ហ្នឹងតែងតែយកធម៌មកពីចារណាជាប់ដែរ គឺសីលធម៌រស់នៅរបស់ខ្ញុំហើយ ខ្ញុំបួសខំរៀនអស់រយៈប៉ុន្មានឆ្នាំមក ក៏តែងតែយកធម៌ព្រះពុទ្ធយកមកដាក់ក្នុងខ្លួនដែរ ដែលខ្លួនបានរៀនខ្លួនបានទន្ទេញប៉ុណ្ណាថាមិនឲ្យសម្លាប់ អតនាទាថាមិនឲ្យលួចទ្រព្យគេ ហ្នឹងចឹងគឺមានសីលប្រាំខ្ញុំតែងតែដុតធូបតែងតែបូងសន្ទ្រូងតែងតែបួងសួងជាប់ដល់គុណ មាតាបីតាគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ។

ដានីៈ ចឹងអ៊ីគិតថាជួយគេថ្ងៃក្រោយមានគេជួយយើងវិញចឹង ចឹងកាលអ៊ីបានជួយគេអស់រយៈ ពេលបីឆ្នាំចឹងមក មកដល់ឥឡូវមានគេតបស្នងអ៊ីវិញទេ?

ប៉ូចៈ ខ្ញុំគឺមិនទាន់មានអីធំទេ គ្រាន់តែគេមកអរគុណយើង ថាអ៊ីយ៉ាងនោះមួយយ៉ាងនេះពី ។

ដានីៈ បាទ ។

ប៉ូចៈ មានថ្ងៃមួយមានប្រជាជនខ្លះគាត់មកថា ដូចថាមិនសមបើនិយាយគាត់ស្លាប់ហើយដូចជា អ៊ីពក ដូចជាមីងមួយដែលខ្ញុំនិយាយហ្នឹងអ៊ីពកគាត់សួរថាម៉េចទៅប្រជាជន គាត់នៅសួរ រកដែលប្តអត់? ហើយយាយនោះគាត់និយាយថាគេមិនសួររកទេអ៊ីឯងនោះ ព្រោះគេ ស្អប់គេដៀលចេះចុះអី ចុះមិត្តប៉ូចយ៉ាងម៉េច? ថាទេគាត់មិនដែលពុទ្ធណាមួយទៅខឹងទៅ ទៅប្រមាថមើលងាយគាត់ទេ ខ្ញុំនិយាយប្រាប់ក្មួយឯងត្រង់ ។

ដានីៈ បាទ ។

ប៉ូចៈ គឺមានព្រឹត្តិការណ៍ឆ្នាំ៧៩ដែលកើតឡើងពេញ ស្រុកបារាយណ៍ហើយហ្នឹងខ្ញុំនៅក្នុងអំឡុង ហ្នឹងមានប្រជាជនប្រាប់ថា ក្មួយអើយគេចសិនទៅក្នុងពេលហ្នឹងមិនដឹងថាមានពីណាស្អប់ ពីណាស្រឡាញ់ទេ មានតែចឹងបាទ ។

ដានីៈ បាទ ។

ប៉ូចៈ ហើយខ្ញុំចូលទៅវិញ គេឲ្យទៅឃោសនាប្រជាជនវិញខ្ញុំក៏ចូលទៅវិញពេលយប់ចូលទៅ តាមផ្ទះចូលទៅជួបក្នុងព្រៃអី ចឹងទៅគេចេះតែលាក់ខ្ញុំរហូតហើយផ្តល់អង្ករស្បៀងមកឲ្យខ្ញុំ ជាប់ចឹងដែរ ។

ដានីៈ ចឹងអ៊ីមានយាយមួយថាតា ពកសួរគាត់ថាមានគេស្អប់គាត់អីចឹង ហើយយាយហ្នឹងគាត់ ឈ្មោះអី?

ប៉ូចៈ ខ្ញុំភ្លេចហើយប្តីគាត់ឈ្មោះ តា អ៊ួ តា អ៊ួនៅត្រពាំងស្រង៉ែសព្វថ្ងៃនេះ ។

ដានីៈ ឆ្នាំណាដែលតា ពកគាត់សួរហ្នឹង?

ប៉ូចៈ ប្រហែលជាឆ្នាំ៩៩ហ្នឹង ។

ដានីៈ ចឹងគាត់ហ៊ាននិយាយនៅមុខតា ពកចឹងដែរ?

ប៉ូចៈ គាត់ហ៊ាន ខ្លាចអីសម័យយើងនេះហើយ ។

ដានីៈ ចឹងប្រជាជននៅបារាយណ៍មានគេស្រឡាញ់អ៊ំច្រើនចឹង?

ប៉ូចៈ បាទ!តាមដែលខ្ញុំធ្លាប់ឆ្លងកាត់ហ្នឹង ដូចជាភាគតិចដែលទេបាទ អ្នកដែលស្អប់នោះណាស់ ។

ដានីៈ បាទ!ក្រោយ៧៩ហើយមានគេបញ្ជូនអ៊ំឲ្យមកឃោសនាប្រជាជនឲ្យចូលក្នុងព្រៃទៀត?

ប៉ូចៈ បាទ ។

ដានីៈ ខាងណាគេបញ្ជាឲ្យអ៊ំទៅ?

ប៉ូចៈ ខាង តា ពកហ្នឹងហើយ ។

ដានីៈ ចឹងកាល៧៩ហ្នឹងបើមានគេស្អប់អ៊ំគេប្រាប់ទៅខាងវៀតណាមហើយ?

ប៉ូចៈ បាទ! មិនបាច់ប្រាប់ទេ គេកាប់យើងក៏ងាប់ដែរ ។

ដានីៈ បាទ ។

ប៉ូចៈ មិនថាចឹងក្លួយជំនាន់ហ្នឹង ។

ដានីៈ ចឹងមានគេតបស្នងមកអ៊ំវិញ គេជួយលាក់អ៊ំ?

ប៉ូចៈ បាទ! ហើយសព្វថ្ងៃនេះខ្ញុំខំតែកសាងតែអំពើល្អដល់ខ្លួនឯងកូនចៅ ។

ដានីៈ ក្រៅពីគ្រួសារតាអ្នួធ្លាប់មកលេងអ៊ំមានគ្រួសារណាផ្សេងទៀត ដែលធ្លាបជួយពួកគាត់ ហើយពួកគាត់នៅតែមានទំនាក់ទំនងជាមួយអ៊ំហើយសព្វថ្ងៃពួកគាត់នៅរស់ដែរ?

ប៉ូចៈ សើច....ដូចជាមិនចាំទេក្លួយ ។

ដានីៈ ចឹងអ៊ំមានអារម្មណ៍យ៉ាងម៉េចដែរ ដែលពួកខ្ញុំមកសួររឿងរ៉ាវដែលអ៊ំធ្លាប់ជួយ គេចឹង ។

ប៉ូចៈ ខ្ញុំអត់មានអារម្មណ៍ប្រែប្រួលទេ ចំពោះក្លួយដែលបានមកសាកសួរពីប្រវត្តិហួរហែររបស់ខ្ញុំនេះ ខ្ញុំមិនអារម្មណ៍អីភ័យព្រួយដោយប្រការណាមួយទេ ខ្ញុំតែងតែអរគុណចំពោះក្លួយ ដែលបានមកសាកសួរអំពីអំពើល្អខ្លះៗអំពីខ្ញុំហ្នឹង ក៏ខ្ញុំរីករាយដល់ក្លួយឥតមានអ៊ីគណនាទេ ខ្ញុំមានតែប៉ុណ្ណឹង ខ្ញុំសព្វថ្ងៃរស់នៅជាប្រជាជនហើយគាត់បានបោះឆ្នោតឲ្យជាក្រុមប្រឹក្សាឃុំនេះ ចេះតែខំប្រឹងជាមួយក្រុមប្រឹក្សាឃុំទាំងអស់ចេះតែធ្វើដើម្បីអភិវឌ្ឍន៍នៅក្នុងភូមិរបស់ខ្លួន ។

ដានីៈ ចឹងអ៊ំអាចណែនាំខ្ញុំថាមានពីណាដែលធ្លាប់ធ្វើការដូចអ៊ំដែលហើយគាត់ធ្លាប់ជួយមនុស្សចឹងដែរ ថាអ៊ំមានស្គាល់ពីណាទៀតជួយណែនាំប្រាប់ខ្ញុំផង?

ប៉ូចៈ ដូចជាអ្នកផ្សេងទៀតកាលជំនាន់ហ្នឹងដូចជាអស់ហើយ អ៊ំ ពកក៏គាត់ស្លាប់ទៅអឿននោះក៏ស្លាប់ទៅមានពីណាទៀត ។

ដានីៈ គាត់មានឋានៈជាឃុំ កងទ័ពក៏បានឲ្យតែគាត់មានតួនាទីកាលសម័យហ្នឹង ឲ្យតែធ្លាប់បានជួយឲ្យផុតពីការស្លាប់?

ប៉ូចៈ ខ្ញុំក្តាប់មិនសូវបានមិនថាគេជួយកំរិតណាៗ អន្លង់វែងត្រពាំងប្រសាទនេះសុទ្ធតែមេអ្នកតស៊ូទាំងអស់ហ្នឹង ។

ដានីៈ នៅត្រពាំងប្រសាទហ្នឹងឈ្មោះអីគេ?

ប៉ូចៈ ឈ្មោះលោកជុំ គាត់ឥឡូវជាអភិបាលរងខេត្តទៅហើយ ។

ដានីៈ ចឹងជំនាន់បីឆ្នាំគាត់ជាអ្វី?

ប៉ូចៈ គាត់នៅខាងទាហានទេ គាត់ខាងទ័ព ។

ដានីៈ ចឹងអ្នកនៅអន្លង់វែងយើងហ្នឹង កាលជំនាន់បីឆ្នាំគាត់មានតួនាទីខាង ខាងឃុំ ខាងតំបន់អីចឹង?

ប៉ូចៈ ស្រីមានតែយាយវ៉ាន់ យាយចែម ។

ដានីៈ យាយវ៉ានគាត់នៅត្រង់ណា?

ប៉ូចៈ គាត់នៅភូមិអភិវឌ្ឍន៍យ៉ាងម៉េចទេ ភូមិគាត់មិនសូវចាំផង ។

ដានីៈ ចឹងសួរគេម្តុំណាគេអាចសួរគាត់?

ប៉ូចៈ ទៅសួរម្តុំភូមិអភិវឌ្ឍន៍ហ្នឹង ។

ដានីៈ យាយវ៉ាន់គាត់មានតួនាទីអីដែរ?

ប៉ូចៈ ទេ ខ្ញុំក្តាប់មិនបានដែរ គាត់ទទួលខាងអីទេ ។

ដានីៈ យាយវ៉ាន់កាលជំនាន់បីឆ្នាំគាត់ធ្វើអី?

ប៉ូចៈ កាលហ្នឹងគាត់នៅឆ្ងាយពីគ្នាដែរ តែពេលមកជួបគ្នានៅជំរំនេះបានស្គាល់គាត់ ។

ដានីៈ ចឹងយាយចែមនៅភូមិណាដែរ កាលខ្ញុំទៅជួបគាត់នៅត្រពាំងថ្មខេត្តបន្ទាយមានជ័យ ខាងភ្នំស្រុក តែឥឡូវគាត់នៅទីណាវិញ?

ប៉ូចៈ ឥឡូវគាត់នៅអូរអង្រែ ឃុំត្រពាំងសោ ។

ដានីៈ គាត់ធ្វើការអីដែរ?

ប៉ូចៈ ឥឡូវគាត់ធ្វើជាជំទប់ទី១ ក្រុមប្រឹក្សាឃុំ ។

ដានីៈ មានស្គាលពីណាទៀត?

ប៉ូចៈ មានខាងទាហានឈ្មោះ ឆាំ ។

ដានីៈ គាត់នៅណា?

ប៉ូចៈ គាត់នៅកងពល៤៣ ។

ដានីៈ គាត់នៅភូមិណា?

ប៉ូចៈ គាត់នៅជិតយាយវ៉ាន់ហ្នឹងដែរ ។

ដានីៈ កាលជំនាន់បីឆ្នាំគាត់ធ្វើអីដែរ?

ប៉ូចៈ	គាត់នៅខាងសាធារណៈការ គាត់នៅជាអ៊ំ ពកដែរ ។

ដានីៈ	មានអ្នកណាទៀត?

ប៉ូចៈ	មានឈ្មោះ ឈាន់នៅខាងគាត់ដែរ ។

ដានីៈ	នៅភូមិអីដែរ?

ប៉ូចៈ	នៅស្វាយចេកនេះ

ដានីៈ	គាត់ស្រីឬប្រុស?

ប៉ូចៈ	ស្រី ។

ដានីៈ	នៅណាដែរ?

ប៉ូចៈ	នៅខាងផ្លូវចេញនៅជិតហាងកែសម្លស្ស ។

ដានីៈ	កាត់ដេរភូមិភាគ?

ប៉ូចៈ	កាលជំនាន់ហ្នឹងចឹងហើយ ។

ដានីៈ	មានពីណាទៀតទេ?

ប៉ូចៈ	ភ្លេចអស់ហើយ ។

ដានីៈ	ចឹងចុងក្រោយអ៊ំមានអីបន្ថែមទៀត នៅអ្វីដែលពួកខ្ញុំមិនទាន់សួរអ៊ំ?

ប៉ូចៈ	អត់មានអីទេក្មួយ អស់ហើយ ។

ដានីៈ	ហើយពត៌មានហ្នឹង តើអ៊ំអនុញ្ញាតិឲ្យខ្ញុំយកទៅសរសេរចុះផ្សាយអីទេ?

ប៉ូចៈ	អាហ្នឹងស្រេចតែក្មួយទេ ខ្ញុំអត់មានជំទាស់អីទេ ។

ដានីៈ	ចឹងខ្ញុំអរគុណអ៊ំច្រើនដែលបានចំណាយពេលវេលាឲ្យខ្ញុំសម្ភាសន៍ សួរទាក់ទងពីប្រវត្តិបីនិងសម័យក្រោយមកហ្នង ខ្ញុំអរគុណអ៊ំច្រើន ។

ប៉ូចៈ	បាទ ។

ចប់